**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៤៣..ស.ស.រ.

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីវាយតម្លៃនិងត្រួតពិនិត្យ វត្ថុសិល្បៈបុរាណខ្មែរ ដែលក្រុមហ៊ុន Toei ជប៉ុនខ្ចីយកទៅតាំងពិពណ៌ នៅប្រទេសជប៉ុនរយៈពេលមួយឆ្នាំ ចាប់ពីខែកញ្ញា ឆ្នាំ ២០០៤

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- យោងតាមតម្រូវការចាំបាច់នៃការងារ

**សម្រេច**

**ប្រការ១:** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីវាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរ ដែលក្រុមហ៊ុន Toei ជប៉ុនខ្ចីយកទៅតាំងពិពណ៌នៅប្រទេសជប៉ុនរយៈពេលមួយឆ្នាំ ចាប់ពីខែកញ្ញាឆ្នាំ ២០០៤ ដែលមានសមាសភាព ដូចតទៅ :

១- សម្តេចព្រះរាម **នរោត្តម បុប្ផាទេវី** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជា ព្រះប្រធាន

២- ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៣- ឯកឧត្តម **ឃឹម សារីទ្ធ** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី និងជា អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

៤- ឯកឧត្តម **សេន ឈឹមនៅ** អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៥- ឯកឧត្តម **ជុំ តឿន** អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សមាជិក

៦- លោក **ពេជ កែវ** អគ្គនាយករងបច្ចេកទេស ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សមាជិកអចិន្ត្រៃយ៍

៧- លោក **ទឹម ទិសិដ្ឋ** ប្រធាននាយកដ្ឋានអប់រំ វប្បធម៌សង្គមកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨- លោក **អ៊ួច ទន** ប្រធាននាយកដ្ឋាន បិតិកភណ្ឌវប្បធម៌ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សមាជិក

៩- លោក **ឃុន សារម៉ែន** ប្រធាននាយកដ្ឋាន សារមន្ទីរ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

**ប្រការ២**- គណៈកម្មការនេះមានភារកិច្ចធ្វើការទំនាក់ទំនងនិងក្រសួងពាក់ព័ន្ធនានា និងក្រុមហ៊ុន **Toei** ដើម្បីរៀបចំការវាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរ សំរាប់ទៅធ្វើការតាំងពិពណ៌ នៅប្រទេសជប៉ុន រយៈពេលមួយឆ្នាំ ចាប់ពី ខែកញ្ញា ឆ្នាំ ២០០៤ ។

**ប្រការ៣**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការ ដែលបានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ